ក្រុមប្រឹក្សាជាតិគាំពារសង្គម

ថ្ងៃទី៣ ខែសីហា ឆ្នាំ២០២៥

# ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥

# មាតិកា

១ ទិដ្ឋភាពទូទៅ

២ អភិក្រមនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា

៣ ធាតុផ្សំនៃប្រព័ន្ធគាំពារសង្គមកម្ពុជា

៤ កិច្ចការឆ្លងវិស័យ

៥ អភិបាលកិច្ចប្រព័ន្ធគាំពារសង្គមកម្ពុជា

៦ យន្តការអនុវត្ត និងយន្តការតាមដាន និងវាយតម្លៃ

# ទិដ្ឋភាពទូទៅ




# ទិដ្ឋភាពទូទៅ

ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥” ត្រូវបានរៀបចំឡើងតាមរយៈការធ្វើបច្ចុប្បន្នកម្ម និងជំនួស ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ដើម្បីធានានិរន្តរភាពនៃការបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យកាន់តែរឹងមាំ មានប្រសិទ្ធភាព និងប្រកបដោយចីរភាព ដែលអាចគ្របដណ្តប់ហានិភ័យនៃវដ្តជីវិត និងឆ្លើយតបនឹងគ្រោះអាសន្ន ឬវិបត្តិនានាជាយថាហេតុ។ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ ធ្វើការផ្លាស់ប្តូរអភិក្រមនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមតាមបែបសរសស្តម្ភ មកជាការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម និងការផ្តល់កិច្ចគាំពារតាមហានិភ័យនៃវដ្តជីវិត ឱ្យស្របតាមការវិវឌ្ឍជាក់ស្តែងនៃសង្គម-សេដ្ឋកិច្ចកម្ពុជា និងនិន្នាការតំបន់ និងសកល។

# អភិក្រមនៃការអភិវឌ្ឍ
# ប្រព័ន្ធគាំពារសង្គមកម្ពុជា

# អភិក្រមនៃការអភិវឌ្ឍ ប្រព័ន្ធគាំពារសង្គមកម្ពុជា



## ចក្ខុវិស័យ

ផ្តល់ការគាំពារដល់ពលរដ្ឋគ្រប់រូបពីអសន្តិសុខប្រាក់ចំណូល ក្នុងអំឡុងពេលប្រឈមនឹងហានិភ័យនានា ក្នុងដំណាក់កាលនីមួយៗនៃវដ្តជីវិត សំដៅលើកកម្ពស់សុខភាព និងសុខុមាលភាពពលរដ្ឋ, កាត់បន្ថយភាពក្រីក្រ វិសមភាពយេនឌ័រ និងវិសមភាពសង្គម ព្រមទាំងពង្រឹងសាមគ្គីភាព និងស្ថិរភាពសង្គម តាមរយៈការបន្តជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យកាន់តែរឹងមាំ, ប្រសិទ្ធភាព និងចីរភាព។

## គោលបំណង

ពង្រឹងការអនុវត្តកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមដែលមានស្រាប់ និងដាក់ចេញនូវកម្មវិធីជាតិជំនួយសង្គម ឬរបបសន្តិសុខសង្គមថ្មីៗ តាមស្ថានភាពជាក់ស្តែងនៃការវិវឌ្ឍនៃសង្គម-សេដ្ឋកិច្ច ដើម្បីផ្តល់ការគាំពារលើសន្តិសុខប្រាក់ចំណូលជូនពលរដ្ឋពេញមួយវដ្តជីវិត ដោយឈរលើគោលការណ៍ "មិនបោះបង់ពលរដ្ឋណាម្នាក់" តាមរយៈការពង្រឹងយន្តការចុះបញ្ជីក្នុងប្រព័ន្ធ និងយន្តការកំណត់អត្តសញ្ញាណពលរដ្ឋគោលដៅ។

# អភិក្រមនៃការអភិវឌ្ឍ ប្រព័ន្ធគាំពារសង្គមកម្ពុជា



## គោលដៅ

១ ពង្រឹងអភិបាលកិច្ចប្រព័ន្ធគាំពារសង្គម ដើម្បីធានាប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព

២ ពង្រឹងប្រសិទ្ធភាពនៃយន្តការផ្តល់អត្ថប្រយោជន៍គាំពារសង្គមជូនដល់ពលរដ្ឋ

៣ ពង្រីកការគ្របដណ្តប់លើហានិភ័យនៃវដ្តជីវិត និងការឆ្លើយតបនឹងគ្រោះអាសន្ន ឬវិបត្តិនានា រួមទាំងបម្រែបម្រួលអាកាសធាតុ

៤ ពង្រឹងការចុះបញ្ជីគាំពារសង្គមប្រកបដោយប្រសិទ្ធភាព បរិយាបន្ន និងឆ្លើយតបនឹងតម្រូវការ

៥ កសាងភាពធន់នៃប្រព័ន្ធគាំពារសង្គមកម្ពុជាទាំងមូល។

# អភិក្រមនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា

## ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍សំខាន់ៗ ដូចខាងក្រោម៖



១. សមធម៌ និងបរិយាបន្ន

២.ភាពគ្រប់គ្រាន់

៣. ស័ក្តិសិទ្ធិភាព

៤.ភាពបត់បែន

៥.ចីរភាព

៦.អភិបាលកិច្ចល្អ

៧. ការឆ្លើយតបនឹងយេនឌ័រ

# អភិក្រមនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា

### ការឆ្លើយតបនឹងគ្រោះអាសន្ន

ការដាក់ចេញគោលការណ៍ណែនាំស្តីពីក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន គឺដើម្បីត្រៀមខ្លួនដោះស្រាយបញ្ហានៅពេលមានវិបត្តិ ឬគ្រោះអាសន្ន រួមទាំងបម្រែបម្រួលអាកាសធាតុ ដែលអាចកើតមានជាយថាហេតុនាពេលអនាគត ដោយផ្តល់ការគាំពារដែលមានលក្ខណៈជាប្រព័ន្ធ អាចព្យាករជាមុន ទាន់ពេល និងមានប្រសិទ្ធភាពដល់ពលរដ្ឋ។

### ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ

ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ គឺជាការប្រមូលផ្តុំកម្មវិធីជាតិជំនួយសង្គមដែលមានលក្ខណៈជាការឧបត្ថម្ភសាច់ប្រាក់ ឱ្យអនុវត្តក្នុងទម្រង់រួមមួយ ក្រោមប្រតិបត្តិករទោល។

- ជាគោលការណ៍ រាជរដ្ឋាភិបាលនឹងពិនិត្យលទ្ធភាពធ្វើសមាហរណកម្មកម្មវិធីជាតិជំនួយសង្គមផ្សេងទៀតទៅក្រោមកញ្ចប់គ្រួសារតាមភាពជាក់ស្តែងនាពេលអនាគត។

### យន្តការជំរុញការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម

ជំរុញនិងលើកទឹកចិត្តក្រុមហ៊ុនសហគ្រាស, គ្រឹះស្ថាន, និយោជក, កម្មករនិយោជិត, បុគ្គលស្វ័យនិយោជន៍ ពិសេសក្រុមបុគ្គលប្រកបវិជ្ជាជីវៈសេរី ឬការងារបែបម៉ៅការ (Casual Workers or work) ឱ្យចុះបញ្ជីជាមួយ ប.ស.ស. ក្នុងគោលបំណងពង្រីកការគ្របដណ្តប់របបសន្តិសុខសង្គមប្រកបដោយសមធម៌ និងបរិយាបន្ន។

# ធាតុផ្សំនៃ
# ប្រព័ន្ធគាំពារសង្គមកម្ពុជា

# ធាតុផ្សំនៃប្រព័ន្ធគាំពារសង្គមកម្ពុជា

- មាតុភាព និងហានិភ័យកុមារភាព
- ហានិភ័យសុខភាព
- ហានិភ័យការងារ
- ពិការភាព
- និកម្មភាព
- ភាពគ្មានជម្រក
- ជរាភាព និងឧត្តរជីវី



# មាតុភាព និងហានិភ័យកុមារភាព

- **កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ៖** បន្តពង្រឹងយន្តការអនុវត្តកម្មវិធី ដោយគិតគូរគ្រប់ដណ្តប់លើកុមារពីអាយុពី ២ឆ្នាំ ដល់៥ឆ្នាំ និងក្រុមគោលដៅផ្សេងទៀត ទៅតាមភាពទ្រទ្រង់បាននៃថវិកា។
- **កម្មវិធីផ្តល់អាហារតាមសាលារៀន៖** ទទួលយកសាលារៀនគោលដៅ ជាជំហានៗពី WFP ដោយសិក្សាលទ្ធភាពក្នុងការគ្របដណ្តប់សាលារៀនគោលដៅផ្សេងទៀត។
- **កម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រ៖** ពិនិត្យលទ្ធភាពដំឡើងកម្រិតប្រាក់ឧបត្ថម្ភ និងពង្រីកការគ្របដណ្តប់ជាជំហានៗ។



# ហានិភ័យសុខភាព

ដោយ **"ផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា ឆ្នាំ២០២៤-២០៣៥"** ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការកាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី**, ក្របខណ្ឌគោលនយោបាយនេះកំណត់ឱ្យផ្តោតការយកចិត្តទុកដាក់ក្នុងការអនុវត្តទិសដៅគោលនយោបាយ និងគោលដៅដាក់លាក់ទាំង៣ ដែលកំណត់ក្នុងផែនទីបង្ហាញផ្លូវនេះ។



# ហានិភ័យការងារ

- បន្តជំរុញការពង្រឹងគុណភាពសេវាព្យាបាល និងការស្តារនីតិសម្បទា។ ប.ស.ស. ត្រូវសហការជាមួយមូលនិធិជនពិការ ធ្វើការសិក្សាអំពីលទ្ធភាពក្នុងការជំរុញការប្រើប្រាស់សេវាស្តារនីតិសម្បទារបស់មជ្ឈមណ្ឌលរបស់រដ្ឋ ឱ្យបានជាអតិបរមា។
- បន្តពិនិត្យឡើងវិញនូវកញ្ចប់អត្ថប្រយោជន៍ឱ្យស្របទៅនឹងកម្រិតភាគទានដែលបានបង់ដោយនិយោជក ព្រមទាំងសិក្សាលទ្ធភាពពង្រីកវិសាលភាពរបបនេះទៅបុគ្គលស្វ័យ-និយោជន៍ ដូចបណ្តាប្រទេសក្នុងតំបន់មួយចំនួន។



# ពិការភាព

- ពង្រឹងយន្តការកំណត់អត្តសញ្ញាណពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន
- ពង្រឹងយន្តការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាពក្រីក្រ ក្នុងកញ្ចប់គ្រួសារ ដើម្បីធានាថាក្រុមគោលដៅទទួលបានការឧបត្ថម្ភពីរាជរដ្ឋាភិបាលពិតប្រាកដ
- បន្តពង្រឹងយន្តការគាំពារផ្នែកពិការភាពនៃរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព ហានិភ័យការងារ និងប្រាក់សោធន ដែលត្រូវផ្តោតសំខាន់លើការស្តារនីតិសម្បទា
- ពិនិត្យលទ្ធភាពក្នុងការគិតគូរផ្តល់ការគាំពារបន្ថែមដល់ជនមានពិការភាព ជាសមាជិកនៃគ្រួសារងាយរងហានិភ័យ ទៅតាមលទ្ធភាពទ្រទ្រង់បាននៃថវិកាជាតិ។



# និកម្មភាព

- បន្តកសាងសមត្ថភាពធនធានមនុស្ស និងស្ថាប័ន ដើម្បីត្រៀមខ្លួនសម្រាប់ការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ នៅពេលសមស្របណាមួយខាងមុខ។
- ពង្រឹងយន្តការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ដល់យុវជននៃគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ព្រមទាំងរៀបចំយន្តការ និងវគ្គសិក្សាដែលសមស្របសម្រាប់ជនមានពិការភាព និងស្ត្រី។
- ធ្វើស្ថាបនូបនីយកម្ម "កម្មវិធីកិច្ចគាំពារសង្គមដើម្បីជម្រុញការចាកចេញពីភាពក្រីក្រ" ដោយផ្អែកលើលទ្ធផលនៃគម្រោងសាកល្បង។
- ជំរុញការធ្វើស្ថាបនូបនីយកម្ម "កម្មវិធីសាច់ប្រាក់ពលកម្ម" ឱ្យទៅជាយន្តការ ក្រោមកិច្ចសម្របសម្រួលរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។
- សិក្សាលទ្ធភាពក្នុងការដាក់ឱ្យដំណើរការកម្មវិធីផ្ដល់ឥណទានសម្រាប់ការសិក្សាថ្នាក់ឧត្តមសិក្សា ដល់និស្សិតដែលមានបំណងចូលរៀនថ្នាក់ឧត្តមសិក្សា។



# ភាពគ្មានជម្រក

- ពិនិត្យលទ្ធភាពផ្តល់ការគាំទ្រផ្នែកលំនៅដ្ឋាន តាមរយៈយន្តការគាំពារសង្គម ដោយធ្វើការសិក្សាសមិទ្ធិលទ្ធភាពក្នុងការរៀបចំកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ទ្រទ្រង់ចំណាយជួលផ្ទះ ជូនដល់សិស្ស និងនិស្សិតដែលមកពីគ្រួសារក្រីក្រ និងងាយរងគ្រោះ និងគ្រួសារងាយរងហានិភ័យដែលអាចចាប់ផ្តើមពីការសាកល្បង។
- សិក្សាសមិទ្ធិលទ្ធភាពក្នុងការដាក់ឱ្យដំណើរការកម្មវិធី "លំនៅឋានតម្លៃសមរម្យ" ក្នុងគោលបំណងផ្តល់លទ្ធភាពជូនប្រជាជនដែលមានចំណូលទាប និងជនងាយរងគ្រោះ ក្នុងការទទួលបានផ្ទះសម្បែងរស់នៅសមរម្យ សុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ។
- សិក្សាសមិទ្ធិលទ្ធភាពក្នុងការផ្តល់ការគាំទ្រសម្រាប់ជួយសម្រួលដល់ក្រុមជនងាយរងគ្រោះដែលកំពុងស្នាក់នៅតាមទីវត្តអារាម និងទីកន្លែងសាសនាដទៃទៀត។



# ជរាភាព និងឧត្តរជីវី

- កែទម្រង់របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលនៃវិស័យសាធារណៈ ដើម្បីធានាចីរភាពជារួម តាមរយៈការបង្វែរមកជាប្រព័ន្ធបង់ភាគទានវិញ ដែលមានសង្គតិភាពជាមួយរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់កម្មករនិយោជិត និងក្រុមពលរដ្ឋដទៃទៀត។
- សិក្សាសមិទ្ធិលទ្ធភាពដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់បុគ្គលស្វ័យនិយោជន៍ ទៅតាមបរិបទជាក់ស្តែង។
- ពិនិត្យលទ្ធភាពក្នុងការដាក់ឱ្យដំណើរប្រព័ន្ធសោធនពហុកម្រិត (Multi-tiers Pension System) ដើម្បីពង្រីកការគ្របដណ្តប់ផ្នែកប្រាក់សោធនដល់ប្រជាជនផ្សេងទៀតដែលមិនទាន់ទទួលបានការគ្របដណ្តប់។



# កិច្ចការផ្លូវវិស័យ

# កិច្ចការឆ្លងវិស័យ

១. ការដោះស្រាយវិវាទ និងការទទួលមតិត្រឡប់

២. ការកំណត់អត្តសញ្ញាណអត្ថគាហក

៣. ប្រព័ន្ធគាំពារសង្គមឌីជីថល

៤. ការបញ្ជ្រាបការយល់ដឹង ទំនាក់ទំនង និងការផ្សព្វផ្សាយ

៥. គោលនយោបាយគាំទ្រប្រព័ន្ធគាំពារសង្គម

៦. យន្តការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ក្នុងប្រព័ន្ធគាំពារសង្គម

# ការដោះស្រាយវិវាទ និងការទទួលមតិត្រឡប់

- ត្រូវរៀបចំដាក់ឱ្យដំណើរការយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ សម្រាប់ប្រព័ន្ធសន្តិសុខសង្គម ទាំងការដោះស្រាយវិវាទនៅកម្រិតប្រតិបត្តិករ និងកម្រិតនិយ័តករ។
- សម្រាប់ប្រព័ន្ធជំនួយសង្គម, យន្តការ និងការគិតគូរខាងលើនេះ អាចត្រូវអនុវត្តផងដែរ។
- ត្រូវគិតគូររៀបចំប្រព័ន្ធគ្រប់គ្រងការទទួលបណ្តឹង មតិត្រឡប់ និងសំណូមពរ ឱ្យមានលក្ខណៈសាមញ្ញ និងងាយស្រួល ដោយបង្កើតនូវជម្រើសច្រើន ទាំងការដាក់ពាក្យដោយផ្ទាល់ ឬតាមប្រព័ន្ធបច្ចេកវិទ្យាទំនើប ដើម្បីឆ្ពោះទៅការធ្វើសុខដុមនីយកម្មប្រព័ន្ធគ្រប់គ្រងការទទួលបណ្តឹង មតិត្រឡប់ និងសំណូមពរសម្រាប់ប្រព័ន្ធគាំពារសង្គម។



# ការកំណត់អត្តសញ្ញាណអត្តគាហក

- បន្តពង្រឹងយន្តការកំណត់អត្តសញ្ញាណអត្តគាហកនៃប្រព័ន្ធគាំពារសង្គមឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ មានលក្ខណៈបត់បែន និងឆ្លើយតបនឹងការប្រែប្រួលនៃជីវភាពរស់នៅ និងស្ថានភាពនៃសមាជិកគ្រួសារបានទាន់ពេល
- អភិវឌ្ឍប្រព័ន្ធកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យឱ្យក្លាយទៅ ជាឆ្អឹងខ្នងនៃមូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម (Social Protection Registry) ដែលជាមូលដ្ឋានទិន្នន័យគោលអនុញ្ញាតឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធធ្វើប្រតិបត្តិការផ្លាស់ប្តូរទិន្នន័យរវាងគ្នានឹងគ្នា។



# ប្រព័ន្ធគាំពារសង្គមឌីជីថល

- កែទម្រង់យន្តការ និងនីតិវិធីនៃការចុះបញ្ជីបច្ចុប្បន្ន ទៅជាការចុះបញ្ជី និងផ្តល់អត្ថប្រយោជន៍គាំពារសង្គមដោយប្រើប្រាស់ Portal រួមលើថ្នាលគាំពារសង្គមឌីជីថល និងធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជីរបស់ប្រតិបត្តិករជាមួយមូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម (Social Protection Registry) ដើម្បីកាត់បន្ថយភាពបែកខ្ញែកនៃប្រព័ន្ធ និងសម្រាលបន្ទុកមន្ត្រីអ្នកអនុវត្តកម្មវិធី។
- អនុវត្ត "ផែនការយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម ២០២៤-២០២៨" ដែលជាចលនាការដ៏សំខាន់ ក្នុងការជំរុញរបៀបវារៈប្រព័ន្ធគាំពារសង្គមឌីជីថល។



# ការបញ្ជ្រាបការយល់ដឹង ទំនាក់ទំនង និងការផ្សព្វផ្សាយ

- បន្តពង្រឹង និងពង្រីកវិសាលភាពនៃយន្តការផ្សព្វផ្សាយជាតិគាំពារសង្គម ឱ្យកាន់តែទូលំទូលាយ ដែលអនុញ្ញាតឱ្យស្ថាប័នពាក់ព័ន្ធទាំងអស់អាចប្រើប្រាស់ជាយន្តការរួមតែមួយ ក្នុងការផ្សព្វផ្សាយ និងភ្ជាប់ទំនាក់ទំនងជាមួយសាធារណជនទូទៅ។
- ពិនិត្យលទ្ធភាពពង្រីកវិសាលភាពនៃយន្តការផ្សព្វផ្សាយអំពីប្រព័ន្ធគាំពារសង្គម ឱ្យកាន់តែទូលាយ ដោយការភ្ជាប់ទំនាក់ទំនងជាមួយអ្នកទទួលផល តាមរយៈបុគ្គលមានប្រជាប្រិយភាព។
- បន្តរៀបចំ និងពង្រីកវេទិកាសប្តាហ៍គាំពារសង្គមកម្ពុជាប្រចាំឆ្នាំ ទៅជាវេទិកាពិភាក្សាកម្រិតតំបន់ និងអន្តរជាតិ។
- ពិនិត្យលទ្ធភាពក្នុងការដាក់បញ្ចូលចំណេះដឹងពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គមទៅក្នុងកម្មវិធីសិក្សាជាតិ ទាំងក្នុងកម្រិតចំណេះទូទៅ និងឧត្តមសិក្សា។



# គោលនយោបាយគាំទ្រប្រព័ន្ធគាំពារសង្គម

- រាជរដ្ឋាភិបាលនឹងពិចារណាដាក់ចេញនូវគោលនយោបាយពន្ធ និងគោលនយោបាយអនុគ្រោះផ្សេងទៀត រួមទាំងការឧបត្ថម្ភធនពីរដ្ឋ សម្រាប់ប្រព័ន្ធគាំពារសង្គម ស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។



# យន្តការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ក្នុងប្រព័ន្ធគាំពារសង្គម

- បន្តពង្រឹងការអនុវត្តយន្តការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ក្នុងគោលបំណងប្រមូលផ្តុំកិច្ចសហប្រតិបត្តិការ, ពង្រឹងគណនេយ្យភាព និងពង្រឹងយន្តការសន្ទនាគោលនយោបាយ ព្រមទាំងពង្រឹងភាពជាដៃគូដែលមានលក្ខណៈស្មើភាពគ្នា និងការគោរពគ្នាទៅវិញទៅមក។



# អភិបាលកិច្ច
# ប្រព័ន្ធគាំពារសង្គមកម្ពុជា

# អភិបាលកិច្ចប្រព័ន្ធគាំពារសង្គមកម្ពុជា

អភិបាលកិច្ចប្រព័ន្ធគាំពារសង្គម ត្រូវបន្តបែងចែកជា ៣ កម្រិត រួមមាន៖

(១) កម្រិតគោលនយោបាយ,

(២) កម្រិតនិយ័តករ,

(៣) កម្រិតប្រតិបត្តិករ

ដើម្បីធានាបាននូវប្រតិតុល្យការរវាងការបំពេញមុខងាររបស់អ្នកដាក់ចេញគោលនយោបាយ អ្នកត្រួតពិនិត្យ និងអ្នកអនុវត្តផ្ទាល់។

# យន្តការអនុវត្ត និង
# យន្តការតាមដាន និង
# វាយតម្លៃ



## យន្តការអនុវត្ត

ផែនការសកម្មភាព នឹងកំណត់សកម្មភាពអាទិភាព លម្អិតសម្រាប់រយៈពេលខ្លី, មធ្យម, និងវែង ដែលបែងចែកជាពីរដំណាក់កាល៖

- ដំណាក់កាលទី១ សម្រាប់ឆ្នាំ ២០២៤-២០៣០
- ដំណាក់កាលទី២ សម្រាប់ឆ្នាំ ២០៣០-២០៣៥

## យន្តការការតាមដាន និងវាយតម្លៃ

យន្តការតាមដាន និងវាយតម្លៃបែងចែកជាពីរ៖

- យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម
- ការតាមដាន និងវាយតម្លៃការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម

សូមអរគុណ !